អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

Extraordinary Chambers
in the Courts of Cambodia

Chambres extraordinaires
au sein des tribunaux cambodgiens

# របាយការណ៍តុលាការ ឆ្នាំ២០១៨-២០២២



## ក្នុងការបោះពុម្ពផ្សាយនេះ...

### បច្ចុប្បន្នភាពអំពីតុលាការ


- សាលដីកាលើបណ្តឹងសាទុក្ខត្រូវបានប្រកាសក្នុងសំណុំរឿង ០០២/០២ (សូមមើលអត្ថបទគោល)
- សំណុំរឿង ០០៣ ០០៤ និង ០០៤/០២ ត្រូវបានបញ្ចប់ដោយអង្គជំនុំជម្រះតុលាការកំពូល (សូមមើលទំព័រ ៤-៥)
- ឯកសារសំណុំរឿងជាង ៤.០០០ ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងគ្រប់សំណុំរឿងទាំងអស់ (សូមមើលទំព័រ ៧)
- កាំង ហ្គេកអ៊ាវ នួន ជា និង អោ អាន បានទទួលមរណភាព (សូមមើលទំព័រ ២)
- អ.វ.ត.ក បានចាប់ផ្តើមផ្លាស់ប្តូរឆ្ពោះទៅបំពេញមុខងារដែលនៅសេសសល់ (សូមមើលទំព័រ ១២)


### សកម្មភាពផ្សព្វផ្សាយ


- សិក្ខាសាលាអំពីជនរងគ្រោះ រយៈពេលបីថ្ងៃត្រូវបានរៀបចំឡើងជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលធាតុចូល លើការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យ នៅក្នុងដំណាក់កាលដែលនៅសេសសល់ (សូមមើលទំ. ៨)
- អ.វ.ត.ក បានសហការរៀបចំការប្រកួតថ្នាក់ជាតិនៃការប្រកួតប្រជែងតុលាការច្បាប់មនុស្សធម៌អន្តរជាតិ (សូមមើលទំព័រ ១០)
- ផ្នែកគាំពារជនរងគ្រោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខ និងផ្នែកកិច្ចការសាធារណៈ បានបន្តការផ្សព្វផ្សាយដល់សាធារណជន (សូមមើលទំព័រ ៩)


# ការប្រកាសសាលដីកា ក្នុងសំណុំរឿង ០០២/០២

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីកាចុងក្រោយក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ព្រៃផ្សៃបំផុតដែលបានកើតឡើងក្នុងអំឡុងពេលខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះបានតម្កល់ការដាក់ពិរុទ្ធភាពលើ ខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបនេះ ពីបទប្រល័យពូជសាសន៍មកលើប្រជាជនវៀតណាមឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (រួមទាំងការសម្លាប់រង្គាល មនុស្សឃាត ការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិក ជនជាតិចាម និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ការដាក់ប្រជាជនជាទាសករនៅតាមសហករណ៍ និងកន្លែងធ្វើការទូទាំងប្រទេស ការនិរទេស ការធ្វើទារុណកម្ម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរួមភេទដោយបង្ខំក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ)។

បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ភស្តុតាងបង្ហាញថា នៅពេលបង្ខំឱ្យរួមភេទ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរួច ជនរងគ្រោះជាបុរសបានទទួលរងនូវផលប៉ះពាល់ដូចជនរងគ្រោះជាស្ត្រីដែរ ហើយថានេះជាទង្វើអមនុស្សធម៌ ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះអំពើអមនុស្សធម៌ផ្សេងទៀតទាក់ទងនឹងជនរងគ្រោះជាបុរស។

អង្គជំនុំជម្រះតុលាការកំពូល នឹងបោះពុម្ពផ្សាយសាលក្រមពេញលេញ បន្ទាប់ពីដំណើរការនៃកែសម្រួលនិងការបកប្រែត្រូវបានបញ្ចប់។

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

Extraordinary Chambers
in the Courts of Cambodia

Chambres extraordinaires
au sein des tribunaux cambodgiens

# បច្ចុប្បន្នភាព អំពីតុលាការ



ការបង្ហាញខ្លួនរបស់ ឌុច ជាលើកចុងក្រោយ ក្នុងនាមជាសាក្សី ក្នុងសវនាការសំណុំរឿង ០០២/០២ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦



នួន ជា ក្នុងពេលប្រកាសសាលក្រមសំណុំរឿង ០០២/០២



ខៀវ សំផន កំពុងឈរស្ដាប់ ខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងប្រកាសសាលក្រម សំណុំរឿង ០០២/០២ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

## សំណុំរឿង ០០១

កាំង ហ្កេកអ៊ាវ (ឌុច) បានទទួលមរណភាពនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ ក្នុងអាយុ ៧៧ឆ្នាំ ខណៈកំពុងជាប់ពន្ធនាគារអស់មួយជីវិត។

## សំណុំរឿង ០០២/០២

### ការជំនុំជម្រះ

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។ អង្គជំនុំជម្រះសាលាដំបូងក៏បានកាត់ទោស នួន ជា ពីអំពើប្រល័យពូជសាសន៍លើជនជាតិចាម ក្រោមគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ។

អង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដោយបូកបញ្ចូលការផ្តន្ទាទោសចុងក្រោយ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះបានជូនដំណឹងអំពីសាលក្រមជាលាយលក្ខណ៍អក្សរពេញលេញ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

### បណ្តឹងសាទុក្ខ

#### ▸ នួន ជា

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយលើកឡើងពីកំហុសអង្គហេតុ/អង្គច្បាប់ចំនួន ៣៥១ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមុននឹងទទួលមរណភាពនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ ក្នុងអាយុ៩៣ឆ្នាំ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខប្រឆាំង នួន ជា ហើយបន្ទាប់មក នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានបញ្ជាក់ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលមិនបានបដិសេធសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទេ ហើយសាលដីកាចុងក្រោយស្តីពីពិរុទ្ធភាព ឬភាពគ្មានទោសពៃររបស់ នួន ជា មិនអាចសម្រេចបាន ដោយសារមរណភាពរបស់ នួន ជា បានរារាំងការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។

#### ▸ ខៀវ សំផន

កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខបន្ទាន់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមោឃភាពសាលក្រមសង្ខេបដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយសារខ្វះទម្រង់ និងប្រកាសថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមិនមានសុពលភាព។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា បណ្តឹងសាទុក្ខបន្ទាន់មិនអាចទទួលយកបាន។



សាធារណជនតម្រង់ជួរចូលរួមសវនាការនៅខែវិច្ឆិកា ឆ្នាំ២០១៩

ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ និងបានដាក់សារណាបណ្តឹងសាទុក្ខជាភាសាបារាំងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ បន្ទាប់ពីទទួលបានការពន្យារពេល និងការកំណត់ទំព័រ។ ខៀវ សំផន បានតវ៉ាក្នុងចំណោមចំណុចផ្សេងៗទៀតថា ការជំនុំជម្រះក្តីគឺផ្អែកលើភស្តុតាងក្រៅវិសាលភាព អង្គជំនុំជម្រះសាលាដំបូងមានវិធីសាស្ត្រតែទៅលើផ្នែកខ្លះនៃភស្តុតាង និងបានប្រព្រឹត្តកំហុសផ្សេងៗទាក់ទងនឹងភស្តុតាងទាំងនោះ គោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភបំពាន ការទទួលខុសត្រូវជាលក្ខណៈបុគ្គលមិនត្រូវបានបង្ហាញឱ្យឃើញ ហើយថាមានកំហុសអង្គហេតុទាក់ទងនឹងតួនាទីនិងការដឹងរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្ម។

### ▸ សហព្រះរាជអាជ្ញា

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ដោយបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយមិនរាប់បញ្ចូលអំពើហិង្សាផ្លូវភេទលើជនរងគ្រោះជាបុរសក្នុងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងទៀត។ ដូចនេះ សហព្រះរាជអាជ្ញា បានស្នើសុំឱ្យមានការកែតម្រូវនូវឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត ដើម្បីឱ្យមានការទទួលស្គាល់ត្រឹមត្រូវនូវអំពើរំលោភដោយបង្ខំដូចគ្នា សម្រាប់ជនរងគ្រោះទាំងបុរស និងស្ត្រី។

សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ខៀវ សំផន កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ដោយលើកហេតុផលថា ខៀវ សំផន ខកខានក្នុងការបង្ហាញពីកំហុសធ្ងន់ណាមួយដែលឈានទៅដល់ការធ្វើអន្តរាគមន៍តាមរយៈបណ្តឹងសាទុក្ខ ហើយបានស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោលបណ្តឹងសាទុក្ខទាំងស្រុង។

### ▸ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីនាំមុខបានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កាលពីខែមករា ឆ្នាំ២០២១ ដោយស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលបណ្តឹងសសាទុក្ខទាំងស្រុង និងតម្កល់ពិរុទ្ធភាព និងការផ្តន្ទាទោសមួយជីវិតដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។

### ▸ អង្គជំនុំជម្រះតុលាការកំពូល

នៅខែមករា ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ពេលសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ សម្រាប់ថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១។ ប៉ុន្តែដោយសារជំងឺរាតត្បាតកូវីដ-១៩ អង្គជំនុំជម្រះបានកំណត់ពេលសវនាការឡើងវិញសម្រាប់ខែសីហា ឆ្នាំ២០២១។ សវនាការលើបណ្តឹងសាទុក្ខត្រូវបានធ្វើឡើងជាលក្ខណៈកូនកាត់ (ដោយផ្ទាល់ និងពីចម្ងាយ) និងដោយគោរពតាមវិធីសាស្ត្រសុវត្ថិភាពកូវីដ-១៩ នៅថ្ងៃទី១៦-១៩ ខែសីហា ឆ្នាំ២០២១។ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីកានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ (សូមមើលអត្ថបទគោល)។



ព្រះសង្ឃចូលរួមស្តាប់ការប្រកាសសាលដីកា សំណុំរឿង ០០២/០២




ការប្រកាសសាលដីកាសំណុំរឿង ០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល



អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ០០៣ (២៧-២៩ វិច្ឆិកា ២០១៩)


ការធ្វើសេចក្ដីសន្និដ្ឋានចំពោះមុខអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០៣


សហព្រះរាជអាជ្ញាអន្តរជាតិ Brenda Hollis ធ្វើសេចក្ដីសន្និដ្ឋានក្នុងសំណុំរឿង ០០៣

# សំណុំរឿង ០០៤/០២ ០០៣ និង ០០៤

## ការិយាល័យសហចៅក្រមស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយផ្សេងគ្នាក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន (១៦ សីហា ២០១៨) សំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត (២៨ វិច្ឆិកា ២០១៨) និង សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ (២៨ មិថុនា ២០១៩) ដោយឆ្លុះបញ្ចាំងពីការសន្និដ្ឋានផ្ទុយគ្នាថា តើជនសង្ស័យស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ហើយដូច្នេះថាតើពួកគេស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ។ បន្ទាប់ពីដំណើរការប្ដឹងតវ៉ានៅចំពោះមុខអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល (ដូចមានសង្ខេបខាងក្រោម) សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ឱ្យបោះត្រា និងបញ្ចូលសំណុំរឿងនៅក្នុងបណ្ណសារ ក្នុងខែសីហា ឆ្នាំ២០២០ (សំណុំរឿង ០០៤/០២) និងខែធ្នូ ឆ្នាំ២០២១ (សំណុំរឿង ០០៣ និងសំណុំរឿង ០០៤)។ ដីកានេះបានបញ្ចប់ដំណើរការនីតិវិធីក្នុងសំណុំរឿងទាំងបី។

## អង្គបុរេជំនុំជម្រះ

ក្នុងសំណុំរឿង ០០៤/០២ អង្គបុរេជំនុំជម្រះ បានបើកសវនាការអសាធារណៈ រយៈពេលបីថ្ងៃ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅថ្ងៃទី១៩-២១ ខែមិថុនា ឆ្នាំ២០១៩។ អង្គបុរេជំនុំជម្រះបានចេញការពិចារណាលើបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដោយប្រកាសថាការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា គឺខុសច្បាប់ ប៉ុន្តែអង្គបុរេជំនុំជម្រះមិនអាចប្រមូលមតិភាគច្រើនបានសម្រាប់ការសម្រេចលើអង្គសេចក្ដីឡើយ។

ក្នុង សំណុំរឿង ០០៣ អង្គបុរេជំនុំជម្រះបានបើកសវនាការរយៈពេលបីថ្ងៃលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី២៧-២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។ អង្គបុរេជំនុំជម្រះបានចេញការពិចារណាលើបណ្ដឹងសាទុក្ខនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ដោយយល់ឃើញថា អង្គបុរេជំនុំជម្រះខ្វះមតិភាគច្រើនដែលចាំបាច់ដើម្បីសម្រេចលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍។ បន្ទាប់ពីការស្នើសុំពីភាគីនានាឱ្យចេញសេចក្ដីសម្រេចបន្ថែមទៀត អង្គបុរេជំនុំជម្រះបានបញ្ជាក់ពីការពិចារណារបស់ខ្លួននៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ដោយប្រកាសថា អង្គបុរេជំនុំជម្រះបានបញ្ចប់ភារកិច្ចទាំងអស់ស្របតាមក្របខ័ណ្ឌច្បាប់។

ក្នុង សំណុំរឿង ០០៤ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដោយមិនបើកសវនាការ ហើយបានចេញការពិចារណាលើបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១។ ដូចករណី ០០៤/០២ និងសំណុំរឿង ០០៣ ដែរ អង្គបុរេជំនុំជម្រះបានរកឃើញថា អង្គបុរេជំនុំជម្រះខ្វះមតិភាគច្រើនដែលចាំបាច់ដើម្បីសម្រេចលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍។

## អង្គជំនុំជម្រះ

បន្ទាប់ពីអង្គបុរេជំនុំជម្រះបានចេញការពិចារណាក្នុងសំណុំរឿង ០០៤/០២ អង្គជំនុំជម្រះសាលាដំបូងបានទទួលសារណាមួយចំនួនពីភាគីក្នុងសំណុំរឿង។ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីថ្លែងការណ៍ថា អង្គជំនុំជម្រះសាលាដំបូងមិនអាចចាត់វិធានការតាមផ្លូវតុលាការពាក់ព័ន្ធនឹង អោ អាន បានទេ ដោយសារមិនទាន់បានទទួលការជូនដំណឹងជាផ្លូវការអំពីសំណុំរឿង ០០៤/០២ និងមិនទាន់បានទទួលសំណុំរឿង។

អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សំណុំរឿងភាគច្រើនមានរក្សាការសម្ងាត់ហើយអង្គជំនុំជម្រះសាលាដំបូងមិនអាចចូលទៅប្រើប្រាស់បានឡើយក្នុងកាលៈទេសៈដែលមិនមានការជូនដំណឹង និងការផ្ទេរឯកសារត្រឹមត្រូវ។ យោងតាមចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង សេចក្ដីថ្លែងការណ៍នេះមិនមានអានុភាពផ្លូវច្បាប់ទេ ប៉ុន្តែចៅក្រមសង្ឃឹមថា វានឹងផ្ដល់តម្លាភាព និងភាពច្បាស់លាស់ដល់សាធារណជន និងភាគីនៃសំណុំរឿង។



បន្ទាប់ពីសេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិបានប្ដឹងសាទុក្ខបន្ទាន់លើសំណុំរឿង ០០៤/០២ ទៅកាន់អង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ដោយស្នើសុំឱ្យបដិសេធចោល "ការរំលត់ជាធរមាន" របស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿងនេះ។ អោ អាន បានដាក់សំណើតបនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ដោយស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយផ្អែកលើមូលដ្ឋានថា មិនអាចទទួលយកបាន ហើយដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបាន "រំលត់សំណុំរឿងជាធរមាន" ឡើយ។

## អង្គជំនុំជម្រះតុលាការកំពូល

បន្ទាប់ពីមានការជាប់គាំងក្នុងសំណុំរឿងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណើពីភាគីដើម្បីដោះស្រាយសំណុំរឿង ០០៤/០២ ០០៣ និង ០០៤។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើរបស់ មាស មុត និង យឹម ទិត្យ ដែលស្នើសុំអន្តរាគមន៍ក្នុងដំណើរការបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹង អោ អាន ហើយនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ បានរកឃើញថា ការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នាហើយខុសច្បាប់ដោយសហចៅក្រមស៊ើបអង្កេត មានន័យថាមិនមានដីកាដំណោះស្រាយណាមួយមានសុពលភាពទេ ហើយគ្មានការបញ្ជូនសំណុំរឿងទៅជំនុំជម្រះណាមួយដែលមានភាពច្បាស់លាស់និងអាចអនុវត្តបានឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា សំណុំរឿង អោ អាន ត្រូវបានបញ្ចប់ (ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០) ហើយបានសន្និដ្ឋានដូចគ្នាទាក់ទងនឹង មាស មុត (១៧ ធ្នូ ២០២១) និង យឹម ទិត្យ (២៩ ធ្នូ ២០២១)។



# ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ ០០៤/០២ និង ០០៤

ជនរងគ្រោះជាង២.០០០នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងមាសមុត(សំណុំរឿង០០៣)យឹមទិត្យ(សំណុំរឿង០០៤) អ៊ឹម ចែម (សំណុំរឿង ០០៤/០១) និង អោ អាន (សំណុំរឿង ០០៤/០២)។ ខណៈពេលដែលសំណុំរឿង ០០៤/០១ ត្រូវបានប្រានចោលដោយសហចៅក្រមស៊ើបអង្កេត ការខ្វែងគំនិតគ្នានៅក្នុងសំណុំរឿងដែលនៅសេសសល់បាននាំឱ្យមានការជំទាស់លើការសម្រេចចិត្តលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើបអង្កេតជាតិបានប្រានចោលរាល់ពាក្យសុំទាំងអស់ក្នុងសំណុំរឿង ០០៣ ០០៤ និង ០០៤/០២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចទទួលយកខ្លះ និងបដិសេធចោលខ្លះ។ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅកាន់អង្គបុរេជំនុំជម្រះមិនមានការទទួលបាននូវសម្លេងភាគច្រើនឡើយ ហើយបន្ទាប់ពីដំណើរការប្តឹងតវ៉ាដ៏យូរ អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថាសំណុំរឿងទាំងបីត្រូវបានបញ្ចប់។

ការបោះពុម្ពលើកក្រោយនៃរបាយការណ៍តុលាការនេះនឹងពិនិត្យឡើងវិញនូវសេចក្តីសម្រេចចិត្តទាំងនេះ ហើយពិភាក្សាអំពីផលប៉ះពាល់ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។



សាធារណជនចូលរួមស្តាប់សវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២



លោកចៅក្រម Philip Rapoza នៃអង្គជំនុំជម្រះតុលាការកំពូល



មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (កណ្តាល និង ស្តាំ) មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (មុខ និង ក្រោយ) ក្នុងពេលប្រកាសសាលដីកាសំណុំរឿង ០០៤/០២

## មន្ត្រីតុលាការ និងប្រធានផ្នែក

**សហចៅក្រមស៊ើបអង្កេត៖** បន្ទាប់ពីការចេញដីកាដំណោះស្រាយចុងក្រោយ ចៅក្រម Michael Bohlander បានលាលែងពីតំណែងនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។ ចៅក្រម បានចូលកាន់តំណែងវិញ បន្ទាប់ពីភាគីបានដាក់ពាក្យស្នើសុំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៤/០២។

**អង្គជំនុំជម្រះសាលាដំបូង៖** បន្តការបញ្ចប់ដំណើរការនៃការជំនុំជម្រះទាំងអស់ ចៅក្រម Jean-Marc Lavergne បានលាលែងពីតំណែង ហើយត្រូវបានជំនួសដោយចៅក្រមបម្រុង Martin G. Karopkin នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។

**អង្គជំនុំជម្រះតុលាការកំពូល៖** ចៅក្រម Maureen Harding Clark ត្រូវបានតែងតាំងនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ជំនួសចៅក្រម Agnieszka Klonowiecka-Milart ដែលបានលាលែងពីតំណែង កាលពីចុងឆ្នាំ២០១៨។ ចៅក្រមបម្រុង Philip Rapoza ត្រូវបានតែងតាំងជាចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ បន្ទាប់ពីការលាលែងពីតំណែងរបស់ចៅក្រម Clark ដោយសារហេតុផលសុខភាព។

**ផ្នែកគាំពារការការពារក្តី៖** ផ្នែកគាំពារការការពារក្តីបានចាត់តាំងអ្នកស្រី Doreen Chen ជនជាតិអូស្ត្រាលី ធ្វើជាមេធាវីតំណាងឱ្យ នួន ជា នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ បន្ទាប់ពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដកឈ្មោះលោក Victor Koppe ចេញពីបញ្ជីមេធាវីបរទេសដែលត្រូវបានអនុញ្ញាតឱ្យបំពេញការងារនៅចំពោះមុខ អ.វ.ត.ក។

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖** លោកស្រី Marie Giraud បានលាលែងពីតំណែងនៅខែមិថុនា ឆ្នាំ២០១៩ ហើយត្រូវបានជំនួសដោយលោកស្រី Megan Hirst ជនជាតិអូស្ត្រាលី ចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។ លោកស្រី Megan Hirst បានលាលែងពីតំណែងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ហើយត្រូវបានជំនួសដោយលោកស្រី Falguni Debnath ជនជាតិកាណាដា ចាប់ពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២។

# ការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារសំណុំរឿង

| | | |
|---|---|---|
| ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៤ ក្នុងសំណុំរឿង ០០៤/០១ | ឯកសារ D309/2/1/7 |
| ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៣ ក្នុងសំណុំរឿង ០០៤/០១ | ឯកសារ D314/2 |
| ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ | អង្គជំនុំជម្រះសាលាដំបូង សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ១.៤៣៩ ក្នុងសំណុំរឿង ០២ | ឯកសារ E467/6 |
| ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៤៧ ក្នុងសំណុំរឿង ០០៤, ០០៤/០១ និង ០០៤/០២ | ឯកសារ D360/30<br>ឯកសារ D359/21 |
| ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ | អង្គបុរេជំនុំជម្រះបា សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៤៣៩ ក្នុងសំណុំរឿង ០០៤/០២ | ឯកសារ D359/38<br>ឯកសារ D360/47 |
| ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ២០៧ ក្នុងសំណុំរឿង ០០៣ | ឯកសារ D266/28<br>ឯកសារ D267/36 |
| ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៣៧៤ ក្នុងសំណុំរឿង ០០៤ | ឯកសារ D381/43<br>ឯកសារ D382/42 |
| ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ១៧៩ ក្នុងសំណុំរឿង ០០៤/០១ | ឯកសារ D315 |
| ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៩៩ ក្នុងសំណុំរឿង ០០៣ | ឯកសារ D266/29<br>ឯកសារ D267/37 |
| ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៦១ ក្នុងសំណុំរឿង ០០៣ | ឯកសារ D316 |
| ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៩៧ នៅក្នុងសំណុំរឿង ០០៤/០២ | ឯកសារ D365 |
| ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៣៦៥ ក្នុងសំណុំរឿង ០០៣ | ឯកសារ D274 |
| ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ៥០៩ ក្នុងសំណុំរឿង ០០៤ | ឯកសារ D387 |
| ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ | អង្គបុរេជំនុំជម្រះ សម្រេចធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារចំនួន ២៧៣ ក្នុងសំណុំរឿង ០០៤/០១ | ឯកសារ D317 |
| ថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ | អង្គជំនុំជម្រះតុលាការកំពូល ចាប់ផ្តើមដំណើរការចំណាត់ថ្នាក់ឡើងវិញលើឯកសារក្នុងសំណុំរឿង ០០២ | ឯកសារ F71/1/1 |

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

Extraordinary Chambers
in the Courts of Cambodia

Chambres extraordinaires
au sein des tribunaux cambodgiens

# ផ្នែកគាំពារជនរងគ្រោះ និងការផ្សព្វផ្សាយសាធារណៈ



ពិធីប្រកាសបើកសិក្ខាសាលាស្តីពីជនរងគ្រោះ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២

## អ.វ.ត.ក រៀបចំ សិក្ខាសាលាអំពីជនរងគ្រោះ

ចាប់ពីថ្ងៃទី៣-៥ ខែឧសភា ឆ្នាំ២០២២ អ.វ.ត.ក បានរៀបចំសិក្ខាសាលាមួយស្តីពី "សកម្មភាពទាក់ទងនឹងជនរងគ្រោះនៃ អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់" ដែលបានប្រព្រឹត្តទៅនៅទីក្រុង ភ្នំពេញ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៩នាក់ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានចូលរួមក្នុងការពិភាក្សាជាក្រុម និងចែករំលែកបទពិសោធន៍របស់ពួកគេ។

ផ្នែកគាំពារជនរងគ្រោះបានចូលរួមយ៉ាងសកម្ម និងសម្របសម្រួលសិក្ខាសាលា រៀបចំឱ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី និងធ្វើការពិភាក្សាជាមួយជនរងគ្រោះ-អ្នកនៅរស់រានមានជីវិត។

សិក្ខាសាលានេះត្រូវបានរៀបចំឡើង បន្ទាប់ពីរបាយការណ៍របស់សហចៅក្រមរបាយការណ៍អំពីសកម្មភាពទាក់ទងនឹងជនរងគ្រោះចុះផ្សាយនៅខែធ្នូ ឆ្នាំ២០២១ បានផ្តល់អនុសាសន៍ឱ្យមានកិច្ចប្រជុំដោយផ្ទាល់រវាងភាគីពាក់ព័ន្ធនឹងជនរងគ្រោះ។ មានការអញ្ជើញចូលរួមពីអ្នកចូលរួមជាង ៩០នាក់ រួមទាំងតំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ ស្ថាប័នរដ្ឋ និងសារមន្ទីរ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញផ្នែកច្បាប់ផ្សេងទៀត និងបុគ្គលិក អ.វ.ត.ក។

ជាជំហានដំបូង សិក្ខាសាលាបានកត់សម្គាល់ការពិចារណា និងការអនុវត្តអាណត្តិដែលនៅសេសសល់របស់ អ.វ.ត.ក។



ជនរងគ្រោះចូលរួមពិភាក្សាតាមក្រុមនៅក្នុងសិក្ខាសាលាស្តីពីជនរងគ្រោះ



អ្នកនៅរស់រានមានជីវិតពីមន្ទីរស-២១ ជុំ ម៉ី (ឆ្វេង) និង ប៊ូ ម៉េង (ស្តាំ) ចូលរួមក្នុងពិធីបើកសិក្ខាសាលាស្តីពីជនរងគ្រោះ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២

## ក្រុមការងារជាមួយអង្គការសង្គមស៊ីវិល ដែលផ្តោតលើជនរងគ្រោះ-អ្នករស់រានមានជីវិត

នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ តំណាង ១៦រូប នៃអង្គការសង្គមស៊ីវិលចំនួន ៩ បានចូលរួមក្នុងកិច្ចប្រជុំ លើកទី ១ នៃក្រុមការងារថ្មីនៃអង្គការសង្គមស៊ីវិល ដោយផ្តោតលើការងារដែលកំពុងបន្ត និងការងារអនាគតរបស់ពួកគេ ដើម្បីបម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះ-អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅ បន្ទាប់ពីមានសិក្ខាសាលាស្តីពីជនរងគ្រោះ នៅខែឧសភា ឆ្នាំ២០២២ ដែលបង្ហាញពីតម្រូវការសម្រាប់ក្រុមការងារសង្គមស៊ីវិល បន្តចូលរួមយ៉ាងសកម្មនៅក្នុងរយៈពេលនៃដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក ទាក់ទងនឹងកម្មវិធីដែលផ្តោតលើជនរងគ្រោះ។

កិច្ចប្រជុំនេះទទួលបានលទ្ធផលជាក់ស្តែងសម្រាប់ការបង្កើតក្រុមការងារថ្មី រួមទាំងផែនការសម្រាប់លេខាធិការដ្ឋានដែលដឹកនាំដោយអង្គការសង្គមស៊ីវិល និង អ.វ.ត.ក។



ការប្រជុំបង្កើតក្រុមការងារអង្គការសង្គមស៊ីវិលដែលផ្តោតលើជនរងគ្រោះ-អ្នកនៅរស់រានមានជីវិតជាមួយនឹង អ.វ.ត.ក នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២



ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមស្តាប់សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ នាខែសីហា ឆ្នាំ២០២១

## ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមសវនាការ

ផ្នែកគាំពារជនរងគ្រោះ បានសម្របសម្រួលដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣៩នាក់ ដើម្បីចូលរួមការប្រកាសសាលក្រមសំណុំរឿង ០០២/០២ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០នាក់ បានចូលរួមក្នុងសវនាការលើបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងខែសីហា ឆ្នាំ២០២១។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤៨នាក់ បានចូលរួមស្តាប់ការប្រកាសសេចក្តីសង្ខេបនៃសាលដីកាលើបណ្តឹងសាទុក្ខក្នុងខែកញ្ញា ឆ្នាំ២០២២។ នៅអំឡុងពេល ប្រកាសសាលដីកានេះ ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសជួបជាមួយមេធាវីរៀងៗខ្លួន ដើម្បីទទួលបានការពន្យល់លម្អិតអំពីសាលដីកា។

## វេទិកាថ្នាក់តំបន់

ដើមបណ្តឹងរដ្ឋប្បវេណីទូទាំងរាជធានីភ្នំពេញ និងខេត្តចំនួនប្រាំពីរផ្សេងទៀត ដូចជា កំពង់ចាម ក្រចេះ ស្វាយរៀង កំពង់ឆ្នាំង សៀមរាប បាត់ដំបង និងកំពត ទទួលបានការជូនដំណឹងអំពីការអភិវឌ្ឍដំណើរការនីតិវិធី និងសំណងរបស់ អ.វ.ត.ក ក្នុងសំណុំរឿង ០០២/០២ ក្នុងវេទិកាតំបន់ចំនួន ១៣ ផ្សេងៗគ្នាដែលបានរៀបចំដោយផ្នែកគាំពារជនរងគ្រោះ៖ ប្រាំមួយនៅឆ្នាំ២០១៨ បួននៅឆ្នាំ២០១៩ និងបីនៅឆ្នាំ២០២២។

សិក្ខាសាលាអំពីសំណង រយៈពេលពីរថ្ងៃលើសំណុំរឿង ០០២ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០១៨ នៅរាជធានីភ្នំពេញដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៧នាក់ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៥នាក់។




ប្រធានផ្នែកគាំពារជនរងគ្រោះលោក ហង្ស វណ្ណៈ ពន្យល់ជនរងគ្រោះ-អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ស្តីពីសំណងក្រៅផ្លូវតុលាការ

## អ.វ.ត.ក រៀបចំការប្រកួតប្រជែងថ្នាក់ជាតិរបស់តុលាការលើច្បាប់មនុស្សធម៌អន្តរជាតិ

នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១ អ.វ.ត.ក បានសហការរៀបចំការប្រកួតថ្នាក់ជាតិរបស់កម្ពុជា នៃការប្រកួតប្រជែងរបស់តុលាការលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលរៀបចំដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។

វគ្គផ្តាច់ព្រ័ត្រ និងពាក់កណ្តាលផ្តាច់ព្រ័ត្រ ត្រូវបានធ្វើឡើងនៅក្នុងសាលសវនាការរបស់ អ.វ.ត.ក ហើយ ត្រូវបានវិនិច្ឆ័យដោយអ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញច្បាប់កម្ពុជា និងបរទេសចំនួនប្រាំពីររូប។

និស្សិតមកពីសាកលវិទ្យាល័យចំនួនបួនបានចូលរួមក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ និងវគ្គផ្តាច់ព្រ័ត្រ។

ក្រុមដែលទទួលបានជ័យលាភី មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានឈានទៅចូលរួមការប្រកួតប្រជែងរបស់តុលាការលើច្បាប់មនុស្សធម៌អន្តរជាតិរបស់កាកបាទក្រហមលើកទី២០ (តំបន់អាស៊ីប៉ាស៊ីហ្វិក) ដែលរៀបចំនៅទីក្រុងហុងកុង (ប៉ុន្តែ រៀបចំតាមប្រព័ន្ធឌីជីថល) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៩-១៣ ខែមីនា ឆ្នាំ២០២២។






## សកម្មភាពផ្សព្វផ្សាយ

- **កម្មវិធីជជែកតាមវិទ្យុ** ចំនួន ១០ ដែលរៀបចំឡើងក្នុងឆ្នាំ២០១៨ ដោយមានអ្នកហៅទូរស័ព្ទចូលជាង ៤០នាក់ បានចូលរួមក្នុងការពិភាក្សាតាមវិទ្យុ និងដោយផ្ទាល់ អំពីសុខភាពផ្លូវចិត្ត សាសនាអំពើហិង្សាផ្អែកលើយេនឌ័រ និងបញ្ហាអន្តរជំនាន់ ដូចជាទស្សនៈរបស់ក្មេងជំនាន់ក្រោយលើកុមារដែលកើតចេញពីការរៀបការដោយបង្ខំ។

- **កិច្ចសន្ទនាអន្តរជំនាន់** ស្តីពីអំពើហឹង្សាផ្អែកលើយេនឌ័រក្នុងរបបខ្មែរក្រហម និងផលប៉ះពាល់នាពេលបច្ចុប្បន្ន ដែលមានការចូលរួមពីនិស្សិតចំនួន ៦៥នាក់ ក្នុងឱកាសខួបលើកទី១០៧ នៃទិវាសិទ្ធិនារីអន្តរជាតិ។

- **បណ្តាញជំនួយផ្នែកច្បាប់** បានរៀបចំកិច្ចប្រជុំពិភាក្សាលើប្រធានបទ "បញ្ហាយេនឌ័រក្នុងចំណាកស្រុកក្នុងប្រទេសកម្ពុជា" (បុគ្គល និងសមាជិកចំនួន ២៣នាក់មកពីអង្គការក្រៅរដ្ឋាភិបាលបាន ចូលរួម) "បញ្ហាអំពើហិង្សាផ្លូវភេទក្នុងការធ្វើចំណាកស្រុកក្នុងប្រទេសកម្ពុជា" និង "សិទ្ធិការងាររបស់កម្មករស្រ្តី និងអំពើហិង្សាផ្លូវភេទនៅក្នុងឧស្សាហកម្មសំណង់ក្នុងប្រទេសកម្ពុជា"។

- **វគ្គបណ្តុះបណ្តាល** អង្គភាពគាំពារជនរងគ្រោះ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "រំញោចយេនឌ័រក្នុងវិវាទអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ" (អ្នកចូលរួមចំនួន ១៥៦ នាក់ចែកជា ៣ ក្រុម៖ ក្រុមមេធាវី ក្រុមមន្រ្តីច្បាប់ អ.វ.ត.ក និងក្រុមនគរបាលយុត្តិធម៌ខេត្តកណ្តាល) វគ្គបណ្តុះបណ្តាលរយៈពេលមួយថ្ងៃស្តីពី "បច្ចេកទេសជំនុំជម្រះក្តីសម្រាប់សំណុំរឿងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ" (មេធាវីចំនួន ៣៣ នាក់បានចូលរួម) "ការត្រួតពិនិត្យ និងវាយតម្លៃគម្រោងឆ្លើយតបនឹងយេនឌ័រ" (បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣៦នាក់) និង "រំញោចយេនឌ័រនៅក្នុងវិវាទអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ" (មន្រ្តីនគរបាលយុត្តិធម៌ ចំនួន ៨៧នាក់ នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល)។

- **ពិព័រណ៍ចល័ត និង កិច្ចសន្ទនាអន្តរជំនាន់** ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបខ្មែរក្រហម និងការបញ្ចាំងភាពយន្តរឿង "ដំបូងគេសម្លាប់ឪពុកខ្ញុំ" ត្រូវបានរៀបចំឡើងក្នុងខែមិថុនា ឆ្នាំ២០២២ នៅខេត្តកោះកុង ដោយមានទស្សនិកជនចំនួន ៤៧០នាក់។



ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងពិធីបង្ហាញពិព័រណ៍ចល័តស្តីពីជនរងគ្រោះខ្មែរក្រហមនៅខេត្តសៀមរាប

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

Extraordinary Chambers
in the Courts of Cambodia

Chambres extraordinaires
au sein des tribunaux cambodgiens

# ផលប៉ះពាល់នៃការរាតត្បាតជំងឺកូវីដ-១៩



លោកចៅក្រមបម្រុង Philip Rapoza (មើលឃើញលើអេក្រង់) តាមដានស្តាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពីចម្ងាយ

ជាមួយនឹងការផ្ទុះនៃជំងឺរាតត្បាតកូវីដ-១៩ អង្គជំនុំជម្រះវិសាមញ្ញបានអនុវត្តវិធានការកាត់បន្ថយហានិភ័យ ដោយអនុលោមតាមបទប្បញ្ញត្តិរបស់កម្ពុជា។ ចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ បុគ្គលិកបានធ្វើការពីចម្ងាយពីគេហដ្ឋានក្នុងរាជធានីភ្នំពេញ។ ការរៀបចំការងារតាមវេន បានដាក់អោយអនុវត្តឡើងវិញបន្ទាប់ពីការផ្ទុះនៃជំងឺកូវីដ-១៩ក្នុងសហគមន៍ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ និងបន្តរហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។

បរិវេណ អ.វ.ត.ក នៅតែបើកពេញមួយកំឡុងពេលនៃការរៀបចំការងារតាមវេនសម្រាប់ការប្រើប្រាស់ក្នុងករណីចាំបាច់ ខណៈដែលសេវាកម្មឌីជីថលរបស់ អ.វ.ត.ក រួមទាំងសេវាអ៊ីមែល និងការចូលប្រើប្រាស់មូលដ្ឋានទិន្នន័យតុលាការ នៅតែបន្តមិនរងផលប៉ះពាល់ដោយជំងឺរាតត្បាត។ សកម្មភាពផ្សព្វផ្សាយ ត្រូវបានកម្រិត ហើយកម្មវិធីកម្មសិក្សាការីបរទេសត្រូវបានផ្អាក។




សហព្រះរាជអជ្ញាតាមដានស្តាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពីសាលសវនាការទីពីរនៃ អ.វ.ត.ក ដែលបានរៀបចំឲ្យសវនាការប្រព្រឹត្តទៅបានដោយសុវត្ថិភាពក្នុងពេលមានជំងឺរាតត្បាតកូវីដ-១៩

សវនាការលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ ត្រូវបានគ្រោងធ្វើក្នុងខែឧសភា ឆ្នាំ២០២១ ប៉ុន្តែត្រូវបានពន្យារពេលទៅខែសីហា។ ផ្នែកគ្រប់គ្រងតុលាការបានសម្របសម្រួលការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល សម្រាប់លក្ខខណ្ឌសុវត្ថិភាពកូវីដ-១៩ ក្នុងអំឡុងពេលសវនាការ៖ ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ភាគីបានបង្ហាញសំណើរបស់ពួកគេដោយសុវត្ថិភាព ពីទីតាំងដាច់ដោយឡែកពីគ្នានៅក្នុងបរិវេណរបស់ អ.វ.ត.ក ដោយមានតែចៅក្រម ក្រឡាបញ្ជី និងបុគ្គលិកតុលាការសំខាន់ៗប៉ុណ្ណោះ មានវត្តមាននៅក្នុងសាលសវនាការធំ។ ចៅក្រម និងភាគីទាំងអស់អាចមើលឃើញ និងស្តាប់គ្នាទៅវិញទៅមក តាមរយៈបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសោតទស្សន៍ដែលបានធ្វើទំនើបកម្ម។ ការបកប្រែជាភាសាខ្មែរ អង់គ្លេស និងបារាំង ត្រូវបានធ្វើឡើងយ៉ាងរលូនពីទីក្រុងភ្នំពេញ និងពីក្រៅប្រទេស។



លោក ខៀវ សំផន (ស្តាំ) និងក្រុមមេធាវីការពារក្តីរបស់គាត់ចូលរួមក្នុងសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២

ដូចរាល់ដង ការផ្សាយផ្ទាល់ជាសាធារណៈ ត្រូវបានធ្វើឡើងតាមប្រព័ន្ធអ៊ីនធឺណិត ខណៈចំនួនអ្នកចូលរួម ក្នុងសាលសាធារណៈរបស់ អ.វ.ត.ក ត្រូវបានកាត់បន្ថយពីចំនួនពេញប្រហែល ៥៥០នាក់ មកត្រឹម ៥០នាក់ (ដើមបណ្តឹងរដ្ឋប្បវេណី ១០ នាក់ តំណាងប្រព័ន្ធផ្សព្វផ្សាយ ១៥ នាក់ សាធារណៈជន ១០ នាក់ និតំណាងអង្គទូត និងតំណាងរដ្ឋាភិបាល ១៥នាក់)។ តាមរយៈការអនុវត្ត វិធានការកាត់បន្ថយហានិភ័យទាំងនេះ និងវិធានការផ្សេងទៀត (ដូចជាអនាម័យចាំបាច់ និងការពាក់ម៉ាស់បិទមុខ ឧបករណ៍ស្កែនកំដៅរាងកាយដោយមិនប៉ះ និងកាតចូលប្រើប្រាស់) មិនមានការកាត់ត្រានូវការឆ្លងជំងឺកូវីដ-១៩ឡើយ។




សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមដានស្តាប់សវនាការបណ្តឹងសាទុក្ខ។ ប្រព័ន្ធសោតទស្សន៍ (កាម៉េរ៉ា អេក្រង់ មីក្រូហ្វូន ឧបករណ៍បំពងសំឡេង) ដែលជួយឲ្យសវនាការប្រព្រឹត្តទៅបាន ក្នុងពេលមានជំងឺរាតត្បាតកូវីដ-១៩ អាចមើលឃើញក្នុងរូបភាពនេះ។




ប្រធានផ្នែកកិច្ចការសាធារណៈ ឯ.ឧ. នេត្រ ភក្ត្រា ពន្យល់ដល់អ្នកកាសែត និងតំណាងបណ្តាញសារព័ត៌មានតាមរយៈកម្មវិធី ស៊ូម (zoom)

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

Extraordinary Chambers
in the Courts of Cambodia

Chambres extraordinaires
au sein des tribunaux cambodgiens

# មុខងារដែលនៅសេសសល់



ឧបនាយករដ្ឋមន្ត្រី ឯ.ឧ. ប៊ិន ឈិន ថ្លែងសុន្ទរកថាជាមួយគ្នានឹងអគ្គលេខាធិការរងសម្រាប់កិច្ចការច្បាប់លោក Stephen Mathias បន្ទាប់ពីមានការប្រកាសសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។ តំណាង អ.វ.ត.ក រដ្ឋាភិបាល និងមន្ត្រីការទូត ក៏មានវត្តមានផងដែរ។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ កិច្ចព្រមព្រៀងបន្ថែមរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានចូលជាធរមានដោយចាប់ផ្តើមការផ្លាស់ប្តូររបស់ អ.វ.ត.ក ទៅកាន់មុខងារដែលនៅសេសសល់ នៅពេលដែល អ.វ.ត.ក បញ្ចប់បន្ទុកការងារតុលាការរបស់ខ្លួន។

កិច្ចព្រមព្រៀងបន្ថែមនេះធ្វើឡើងតាមសំណើនៅខែកញ្ញា ឆ្នាំ២០១៨ សម្រាប់ការពិគ្រោះយោបល់រវាងអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា និង អ.វ.ត.ក ដើម្បីបង្កើតក្របខ័ណ្ឌសម្រាប់ការបញ្ចប់អាណត្តិរបស់ អ.វ.ត.ក និងដើម្បីកំណត់មុខងារដែលនៅសេសសល់។ ការពិគ្រោះយោបល់ទាំងនេះបានធ្វើឡើងនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ខែកុម្ភៈ ឆ្នាំ២០១៩។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងខែកក្កដា ឆ្នាំ២០២១ (សូមមើល A/RES/75/257 B) ហើយត្រូវបានអនុម័តជាច្បាប់កម្ពុជាក្នុងខែវិច្ឆិកា។

មុខងារសេសសល់ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងបន្ថែម រួមមាន៖

- ការពិនិត្យឡើងវិញនូវសំណើសុំការពិនិត្យឡើងវិញលើសាលដីកាចុងក្រោយ
- ការផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី
- ការដាក់ទណ្ឌកម្ម ឬបញ្ជូនករណីនៃការជ្រៀតជ្រែកដោយចេតនាក្នុងការគ្រប់គ្រងយុត្តិធម៌
- ត្រួតពិនិត្យការអនុវត្តទោស
- តាមដានការការប្រព្រឹត្តទៅលើពិរុទ្ធជន
- ការថែទាំ ថែរក្សា និងគ្រប់គ្រងបណ្ណសាររបស់ អ.វ.ត.ក រួមទាំងការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ
- ឆ្លើយតបទៅនឹងសំណើសុំចូលប្រើប្រាស់ឯកសារ
- ការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទាក់ទងនឹង អ.វ.ត.ក
- ត្រួតពិនិត្យការអនុវត្តការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី

អ.វ.ត.ក នឹងអនុវត្តមុខងារដែលនៅសេសសល់ទាំងនេះសម្រាប់រយៈពេលបីឆ្នាំដំបូង នៅពេលដែលដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ត្រូវបានបញ្ចប់។

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

Extraordinary Chambers
in the Courts of Cambodia

Chambres extraordinaires
au sein des tribunaux cambodgiens

# ដីកា និងសេចក្ដីសម្រេចរបស់តុលាការ

## ឆ្នាំ២០១៨

| | | |
|---|---|---|
| ថ្ងៃទី១៦ ខែសីហា | សហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយផ្សេងគ្នា ក្នុងសំណុំរឿង ០០៤/០២ ប្រឆាំង អោ អាន | ឯកសារ D359<br>ឯកសារ D360 |
| ថ្ងៃទី១៦ ខែវិច្ឆិកា | អង្គជំនុំជម្រះសាលាដំបូង ប្រកាសសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ | ឯកសារ E465 |
| ថ្ងៃទី២៨ ខែវិច្ឆិកា | សហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយផ្សេងគ្នា ក្នុងសំណុំរឿង ០០៣ ប្រឆាំង មាស មុត | ឯកសារ D266<br>ឯកសារ D267 |

## ឆ្នាំ២០១៩

| | | |
|---|---|---|
| ថ្ងៃទី១៣ ខែកុម្ភៈ | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្ដីសង្ខេបនៃសាលក្រម ក្នុងសំណុំរឿង ០០២/០២ | ឯកសារ E463/1/3 |
| ថ្ងៃទី២៨ ខែមិថុនា | សហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយផ្សេងគ្នា ក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ | ឯកសារ D381<br>ឯកសារ D382 |
| ថ្ងៃទី១៣ ខែសីហា | អង្គជំនុំជម្រះតុលាការកំពូល បញ្ចប់ដំណើរការនីតិវិធីលើ នួន ជា | ឯកសារ F46/3 |
| ថ្ងៃទី២២ ខែវិច្ឆិកា | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹង ផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្រោយមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា | ឯកសារ F46/2/4/2 |
| ថ្ងៃទី១៩ ខែធ្នូ | អង្គបុរេជំនុំជម្រះ ចេញការពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៤/០២ | ឯកសារ D359/24<br>ឯកសារ D360/33 |

## ឆ្នាំ២០២០

| | | |
|---|---|---|
| ថ្ងៃទី៦ ខែមករា | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្ដីសម្រេចលើសំណើសុំភស្តុតាងបន្ថែមរបស់ ខៀវ សំផន | ឯកសារ F51/3 |
| ថ្ងៃទី២៩ ខែមករា | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យបដិសេធសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី | ឯកសារ F50/1/1/2 |
| ថ្ងៃទី១៧ ខែមិថុនា | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្ដីសម្រេចបដិសេធសំណើរបស់ មាស មុត និង យឹម ទិត្យ ដែលសុំអន្តរាគមន៍លើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០៤/០២ | ឯកសារ E004/2/4/1<br>ឯកសារ E004/2/2/1 |
| ថ្ងៃទី៣០ ខែមិថុនា | អង្គបុរេជំនុំជម្រះ ចេញសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/០២ | ឯកសារ D362/6 |

| | | |
|---|---|---|
| ថ្ងៃទី៦ ខែកក្កដា | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការមិនអនុវត្តន៍របស់ ខៀវ សំផន តាមមាត្រា ៦ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ | ឯកសារ F56/2/2 |
| ថ្ងៃទី១៤ ខែកក្កដា | អង្គជំនុំជម្រះតុលាការកំពូល (ក្រុមប្រឹក្សាជំនួស) ចេញសេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន ដែលប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះតុលាការកំពូលចំនួនប្រាំមួយរូប ដែលបានជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ | ឯកសារ 11 |
| ថ្ងៃទី១០ ខែសីហា | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្តីសម្រេចបញ្ជាក់ពីស្ថានភាពនៃសំណុំរឿង ០០៤/០២ | ឯកសារ E004/2/1/1/2 |
| ថ្ងៃទី១៤ ខែសីហា | សហចៅក្រមស៊ើបអង្កេត ចេញដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/០២ ទៅក្នុងបណ្ណសារ | ឯកសារ D363/3 |

## ឆ្នាំ២០២១

| | | |
|---|---|---|
| ថ្ងៃទី៧ ខែមេសា | អង្គបុរេជំនុំជម្រះ ចេញសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៣ | ឯកសារ D266/27<br>ឯកសារ D267/35 |
| ថ្ងៃទី២០ ខែឧសភា | សហចៅក្រមស៊ើបអង្កេត ចេញសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង | ឯកសារ D270/7 |
| ថ្ងៃទី១០ ខែមិថុនា | អង្គបុរេជំនុំជម្រះ ចេញសេចក្តីពិចារណាលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣ | ឯកសារ D269/4 |
| ថ្ងៃទី៨ ខែកញ្ញា | សហចៅក្រមស៊ើបអង្កេត ចេញសេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបញ្ចប់ ឬបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង | ឯកសារ D271/5<br>ឯកសារ D272/3 |
| ថ្ងៃទី១៧ ខែកញ្ញា | អង្គបុរេជំនុំជម្រះ ចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ | ឯកសារ D381/45<br>ឯកសារ D382/43 |
| ថ្ងៃទី២៩ ខែកញ្ញា | អង្គបុរេជំនុំជម្រះ ចេញសេចក្តីពិចារណាលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ | ឯកសារ D384/7 |
| ថ្ងៃទី១៧ ខែធ្នូ | អង្គជំនុំជម្រះតុលាការកំពូលចេញ ចេញសេចក្តីសម្រេចបញ្ជាក់ពីស្ថានភាពនៃសំណុំរឿង ០០៣ | ឯកសារ 3/1/1/1 |
| ថ្ងៃទី២០ ខែធ្នូ | សហចៅក្រមស៊ើបអង្កេត បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ | ឯកសារ D275 |
| ថ្ងៃទី២៨ ខែធ្នូ | អង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្តីសម្រេចបញ្ជាក់ពីស្ថានភាពនៃសំណុំរឿង ០០៤ | ឯកសារ 2/1/1/1 |
| ថ្ងៃទី២៩ ខែធ្នូ | សហចៅក្រមស៊ើបអង្កេត បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ | ឯកសារ D388 |

## ឆ្នាំ២០២២

| | | |
|---|---|---|
| ថ្ងៃទី២២ ខែកញ្ញា | អង្គជំនុំជម្រះតុលាការកំពូល ប្រកាសសេចក្តីសង្ខេបនៃសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ | ឯកសារ F76.1 |

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា




# ព័ត៌មានបន្ថែមស្តីពីអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា


**អាសយដ្ឋានសម្រាប់ផ្ញើសំបុត្រ**

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ
ប្រអប់សំបុត្រលេខ ៧១
ភ្នំពេញ កម្ពុជា

**ទំនាក់ទំនងទូទៅ**

| | |
|---|---|
| ទូរសព្ទលេខ៖ | ៨៥៥ (០) ២៣ ៨៦១ ៥០០ |
| ទូរសារលេខ៖ | ៨៥៥ (០) ២៣ ៨៦១ ៥៥៥ |

**ទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន**

| | |
|---|---|
| ទូរសព្ទលេខ៖ | ៨៥៥ (០) ២៣ ៨៦១ ៦៦៩ |
| ទូរសារលេខ៖ | ៨៥៥ (០) ២៣ ៨៦១ ៥៦៤ |

**ទស្សនកិច្ចតុលាការ**

| | |
|---|---|
| ទូរសព្ទលេខ៖ | ៨៥៥ (០) ២៣ ៨៦១ ៦៣៩ |

**ផ្នែកគាំពារជនរងគ្រោះ**

| | |
|---|---|
| ទូរសព្ទលេខ ៖ | ៨៥៥ (០) ២៣ ២១៤ ២៩១ |


**អាសយដ្ឋាន អនឡាញ**

| | |
|---|---|
| ECCC | www.eccc.gov.kh |
| UNAKRT | www.unakrt-online.org |
| Twitter | twitter.com/KRTribunal |
| Flickr | www.flickr.com/krtribunal |
| Facebook | www.facebook.com/krtribunal |
| Youtube | www.youtube.com/krtribunal |